**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលព្រៃឈើ
នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

ភ្នំពេញ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៤

ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV/REL)

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**តាមរយៈ:** ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV) លើកទី១២។

**ជូនភ្ជាប់:** -បញ្ជីវត្តមាន...........................................................................................ចំនួន១ច្បាប់

-របៀបវារៈនៃកិច្ចប្រជុំ...........................................................................ចំនួន១ច្បាប់

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ យើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា កាលពីថ្ងៃទី២៥-២៦ ខែកក្កដា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេស វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ (MRV/REL)បានរៀបចំកិច្ចប្រជុំលើកទី១២ នៅសណ្ឋាគារ ឯករាជ្យ ក្នុងខេត្តព្រះសីហនុ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

## ១.សមាសភាពចូលរួម

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ១៧ នាក់ (ដូចបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់) មកពី៖

-រាជរដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ក្រសួងបរិស្ថាន ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងរ៉ែ និងថាមពល ក្រសួងមហាផ្ទៃ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

-ក្រុមប្រឹក្សាយោបល់ៈ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ(FAO) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) សមាគមន៍ជនជាតិដើមភាគតិចកម្ពុជា (CIYA) ។

## ២.គោលបំណងនៃអង្គប្រជុំ

គោលបំណងនៃអង្គប្រជុំគឺធ្វើការពិភាក្សាអំពី៖

- លទ្ធផលនៃការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការចាត់ថ្នាក់គម្របព្រៃឈើ និងគម្របដី (LCCS: Land Cover Classification System)
- ចំណាត់ថ្នាក់គម្របព្រៃឈើ និង គម្របដី សម្រាប់អនុវត្តរេដ
- បញ្ជីសំណួរ សម្រាប់ធ្វើការសិក្សាពីតម្រូវការពង្រឹងសមត្ថភាពមន្ត្រីក្នុងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ (GHG Inventory)
- សេចក្តីព្រាងប្រព័ន្ធត្រួតពិនិត្យតាមដានព្រៃឈើថ្នាក់ជាតិ

## ៣.ដំណើរការកិច្ចប្រជុំ

- លោក **ឡេង ជីវិន** និង លោក **Emiliano Stefanini** ទីប្រឹក្សារបស់អង្គការស្បៀង និងកសិកម្ម នៃ សហប្រជាជាតិ (FAO) បានធ្វើបទបង្ហាញរួមមួយស្តីពីលទ្ធផល នៃវគ្គបណ្តុះបណ្តាល ប្រព័ន្ធចាត់ថ្នាក់គម្របព្រៃឈើ និងគម្របដី (LCCS) ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២១ ដល់ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៤ នៅសណ្ឋាគារ រ៉ាហ្វល់ ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ ។ វគ្គបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួមចំនួន ២៥នាក់មកពី៖ រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានកសិកម្ម រដ្ឋបាលជលផល ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ គណៈកម្មការជាតិ ទន្លេមេគង្គ កម្ពុជា (CNMC) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន និង អង្គការស្បៀង និងកសិកម្ម នៃ សហប្រជាជាតិ។ គោលបំណងចម្បងនៃវគ្គបណ្តុះបណ្តាលគឺ ដើម្បីកសាងសមត្ថភាពជំនាញដល់មន្ត្រីបច្ចេកទេស លើប្រព័ន្ធចាត់ថ្នាក់គម្របព្រៃឈើ និងគម្របដី ដើម្បីគាំទ្រដល់ដំណើរការកម្មវិធីរេដបូកនៅកម្ពុជា។ វគ្គបណ្តុះបណ្តាល បានណែនាំសិក្ខាកាមនូវ៖

-របៀបនៃការបញ្ចូលកម្មវិធី Quantum GIS, Google Earth, LCCS3 និង Java ចូលក្នុងកុំព្យូទ័រ

-របៀបនៃការគូសព្រំប្រទល់នៃការប្រើប្រាស់ដីនៅលើកម្មវិធី Google Earth

-វិធីនៃការបង្កើតចំណាត់ថ្នាក់គម្របព្រៃឈើ និងគម្របដីនៅក្នុងកម្មវិធី LCCS3

និងផ្តល់ឱកាសអោយសិក្ខាកាមទាំងអស់ អនុវត្តការប្រើប្រាស់កម្មវិធីទាំងអស់ខាងលើ ក្នុងរយៈពេលពេញមួយថ្ងៃ ដើម្បីអោយសិក្ខាកាមទាំងអស់ធ្វើការស្វែងយល់កាន់តែច្បាស់ពីវិធីនៃការប្រើប្រាស់កម្មវិធធីទាំងនោះ។

លោក **ឡេង ជីវិន** និង លោក **Emiliano Stefanini** ក៏មានធ្វើបទបង្ហាញអំពី ចំណាត់ថ្នាក់គម្របព្រៃឈើ និងគម្របដី ដែលមានលក្ខណៈរួមមួយ សម្រាប់គ្រប់ស្ថាប័នពាក់ព័ន្ធប្រើប្រាស់ក្នុងការអនុវត្តកម្មវិធីរេដបូកនៅកម្ពុជា និងជាចំណាត់ថ្នាក់ដែលជាលទ្ធផលទទួលបានពីកិច្ចពិភាក្សាក្នុងវគ្គបណ្តុះបណ្តាលLCCS។ បន្ទាប់មក ចំណាត់ថ្នាក់ទាំងនេះ បានដាក់អោយសមាជិកនៃអង្គប្រជុំធ្វើការពិភាក្សាសម្រេច

- បន្ទាប់មក លោក **អ៊ុយ កាម៉ាល់** ធ្វើការបង្ហាញសង្ខេបអំពីគម្រោងរៀបចំវគ្គបណ្តុះបណ្តាល ស្តីអំពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ (GHG Inventory) សម្រាប់ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV/REL)

- បន្ទាប់មកទៀត លោក **Mathieu Van Rijn** (FAO) បានធ្វើបទបង្ហាញពីបញ្ជីសំណួរ សម្រាប់ធ្វើការសិក្សាពីតម្រូវការពង្រឹងសមត្ថភាពមន្ត្រីក្នុងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្ត សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ (GHG Inventory)

- ជាចុងក្រោយ លោក **Shigeru Ono** (JICA CAM-REDD) បានធ្វើបទបង្ហាញស្តីពីសេចក្តីព្រាងប្រព័ន្ធត្រួតពិនិត្យព្រៃឈើថ្នាក់ជាតិ (NFMS: National Forest Monitoring System)។

## ៤.លទ្ធផលនៃកិច្ចប្រជុំ

### ៤.១ លទ្ធផលនៃការរៀបចំវគ្គបណ្តុះបណ្តាល LCCS

វគ្គបណ្តុះបណ្តាលនេះ ប្រព្រឹត្តទៅទទួលបានជោគជ័យ ប៉ុន្តែការយល់ដឹងលើការប្រើប្រាស់កម្មវិធី LCCS នៅមានកម្រិតនៅឡើយ ពីព្រោះវគ្គបណ្តុះបណ្តាលមានរយៈពេលខ្លីពេក។

### ៤.២ ចំណាត់ថ្នាក់គម្របព្រៃឈើ និងគម្របដី

ចំណាត់ថ្នាក់ដែលលើកយកមកសម្រាប់ក្រុមការងារបច្ចេកទេស ធ្វើការពិភាក្សានាពេលនេះមានចំនួន ២១ ថ្នាក់ ដូចខាងក្រោម៖

- ព្រៃស្រោង (Evergreen Forest)
- ព្រៃពាក់កណ្តាលស្រោង (Semi-Evergreen Forest)
- ព្រៃល្បោះ (Deciduous Forest)
- ព្រៃលិចទឹក (Flooded Forest)
- ព្រៃកោងកាង (Mangrove)
- ព្រៃស្មាច់ (Rear Mangrove)
- ព្រៃស្រល់ (Pine Tree)
- ព្រៃឬស្សី (Bamboo)
- ព្រៃដុះឡើងវិញ (Regrow Forest)
- ផ្លូវទឹក (Water)
- តំបន់ដីសើម (Wet Land)
- ចំការដូងប្រេង (Oil Plantation)
- ចំការឈើដាំ (Tree Plantation)
- ចំការកៅស៊ូ (Rubber Plantation)
- វាលស្មៅ (Grass Land)
- ដីស្រែ (Paddy Field)
- ដីចំការ (Crop Land)
- ទីក្រុង/ទីប្រជុំជន (Urban/ Build up)
- ដីទំនេរ (Bare Land)
- ដំណាំក្នុងភូមិ (Village Garden)
- ពពក/ស្រមោល (Cloud/Shadow)

ជាលទ្ធផលនៃកិច្ចពិភាក្សា អង្គប្រជុំសម្រេចដូចខាងក្រោម៖

- ស្នើសុំលុបចោលចំណាត់ថ្នាក់ ចំនួនពីរគឺ ពពក/ស្រមោលពពក(Cloud/Shadow) ដំណាំក្នុងភូមិ (Village Garden)

- ស្នើសុំបន្ថែមអនុថ្នាក់ចំនួនពីរ ក្នុងថ្នាក់ដីស្រែ (Paddy Field) គឺអនុថ្នាក់វាលស្រែប្រើទឹកភ្លៀង (Rain Feed) និង អនុថ្នាក់វាលស្រែប្រើប្រព័ន្ធស្រោចស្រព (Irrigate)

- ស្នើសុំធ្វើការសិក្សាលម្អិតបន្ថែមលើចំណាត់ថ្នាក់ចំនួន បួនគឺៈ

**ក. ព្រៃស្រល់** (Pine Tree) គួរបែងចែក និងបង្កើតអនុថ្នាក់ព្រៃស្រល់ធម្មជាតិ និងព្រៃស្រល់ដាំ

**ខ. ព្រៃដុះឡើងវិញ** (Regrow Forest) គួរធ្វើការពិភាក្សាបន្ថែមជាមួយអ្នកជំនាញបច្ចេកទេស មុននឹងដាក់ចំណាត់ថ្នាក់នេះ សុំការឯកភាពប្រើប្រាស់

**គ. ដីទំនេរ** (Bare Land): តំបន់ឆ្នេរសមុទ្រ និងតំបន់ភ្នំដែលមានថ្មច្រើន

**ឃ.តំបន់ដីសើម** (Wet Land): តំបន់តាមដងទន្លេមេគង្គ និងទន្លេសាប

### ៤.៣ គម្រោងរៀបចំវគ្គបណ្តុះបណ្តាលសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់

អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) សហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន គ្រោងរៀបចំវគ្គបណ្តុះបណ្តាលសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ (GHG Inventory) ក្នុងគោលបំណងបីគឺ៖

- ពាំនាំចំណេះដឹងទូទៅអំពីបម្រែបម្រួលអាកាសធាតុ ជូនដល់ក្រុមការងារ (MRV/REL)

- ឱ្យក្រុមការងារ (MRV/REL) ធ្វើការស្វែងយល់អំពីមាតិកា និងកិច្ចដំណើរការនៃការរៀបចំរបាយការណ៍សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់

- បង្កើនគុណភាព និងបរិមាណនៃបោះជំហ៊ាន របស់ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ដែលមានប្រភពមកពីការប្រើប្រាស់ដី បម្រែបម្រួលការប្រើប្រាស់ដី និង ព្រៃឈើ (LULUCF)។

វគ្គបណ្តុះបណ្តាលនេះគ្រោងរៀបចំឡើងចំនួនបីលើកបន្តបន្ទាប់គ្នាដូចរៀបរាប់ខាងក្រោម៖

- លើកទី១៖ គ្រោងនឹងធ្វើនៅថ្ងៃទី ១១-១២ ខែសីហា ឆ្នាំ២០១៤ នៅខេត្តកំពង់ចាម

- លើកទី២៖ គ្រោងនឹងធ្វើនៅថ្ងៃទី១-២ ខែកញ្ញា ឆ្នាំ២០១៤ នៅខេត្តបាត់ដំបង

- លើកទី៣៖ គ្រោងនឹងធ្វើនៅថ្ងៃទី ១-២ ខែតុលា ឆ្នាំ២០១៤ នៅខេត្តរតនៈគីរី

ប្រសិនបើមានការផ្លាស់ប្តូរការបរិច្ឆេទ និងទីកន្លែង ក្រុមការងារនឹងធ្វើការជូនដំណឹងតាមពេលក្រោយ

**៤.៤ បញ្ជីសំណួរសម្រាប់ធ្វើការវាយតម្លៃការពង្រឹងសមត្ថភាពលើ GHG Inventory**

បញ្ជីសំណួរត្រូវការកែសម្រួលចំនុចមួយចំនួនឲ្យសមស្របទៅនឹងការងាររបស់ MRV ។ ក្រុមការងារបានសម្រេចឲ្យលោក **សៀក សុជាត** មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ធ្វើការកែលសម្រួលលើបញ្ជីសំណួរជាមួយលោក Mathieu Van Rijn ហើយបញ្ជូនឲ្យក្រុមការងារពិនិត្យម្តងទៀតក្នុងពេលប្រជុំលើកក្រោយ ។

៤.៤ សេចក្តីព្រាងប្រព័ន្ធត្រួតពិនិត្យព្រៃឈើថ្នាក់ជាតិ (NFMS)

សេចក្តីព្រាង NFMS នេះត្រូវបានធ្វើឡើងដោយផ្អែកលើឯកសារយោងមួយរបស់ UN-REDD បោះពុម្ពក្នុងឆ្នាំ២០១៣។ NFMS នេះមានមុខងារពីរយ៉ាងគឺ មុខងារខាងត្រួតពិនិត្យ និងមុខងារ MRV (វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់) ។

- មុខងារត្រួតពិនិត្យមានន័យថា ធ្វើការផ្ទៀងផ្ទាត់តាមដានការអនុវត្តសាកល្បងនានាក្នុងជំហ៊ានទីពីររបស់រេដបូក និងធ្វើការត្រួតពិនិត្យលើការគាំទ្រផ្នែកនយោបាយ ជាមួយនិងវិធានការមួយចំនួនក្នុងការអនុវត្តជំហ៊ានទីបី (បញ្ជាក់៖ក្នុងដំណើរការអនុវត្តរេដបូករួមមានបីជំហ៊ាន ទីមួយការរៀបចំ ទីពីការសាកល្បង និងទីបីការអនុវត្ត ដែលកម្ពុជា សព្វថ្ងៃកំពុងស្ថិតក្នុងជំហានទីមួយនៅឡើយ)
- មុខងារMRVមានន័យថា ត្រូវធ្វើការលើប្រព័ន្ធគ្រប់គ្រងដីតាមរយៈផ្កាយរណប ការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិ និងការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ។

## ៥.ទិសដៅអនុវត្តបន្ត

-ក្រុមការងារនឹងរៀបចំប្រជុំលើកទី១៣ នៅថ្ងៃទី ៥ ខែសីហា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ដើម្បីធ្វើការពិភាក្សាពីវឌ្ឍនភាពការងាររបស់ក្រុម(MRV/REL) មុននឹងយកទៅធ្វើបទបង្ហាញនៅក្នុងកិច្ចប្រជុំគណៈកម្មាភិបាលកម្មវិធី UN-REDD កម្ពុជា (PEB Meeting) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៤។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាពិនិត្យសម្រេចដោយអនុគ្រោះតាមការគួរ ។

លេខ...១៩៨.......នពស

បានឃើញ និង បញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

"សូមមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះ "

ភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៤

**ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ**

# រូបថតសកម្មភាពនៃកច្ចប្រជុំ MRV លើកទី១២



©Figure 1: Photo of Special MRV TT Meeting 24-26 July 2014 at Independence Hotel, Sihanouk Ville



©Figure 1: Photo of Special MRV TT Meeting 24-26 July 2014 at Independence Hotel, Sihanouk Ville